# របាយការណ៍រួមរបស់អង្គការក្រៅរដ្ឋាភិបាល ស្តីពី <u>សេរីភាពបញ្ចេញមតិនិងការជួបប្រជុំ</u> សំរាប់ការត្រួតពិនិត្យជាសកលតាមពេលកំណត់នៃការបំពេញកាតព្វកិច្ចនិងការប្តេជ្ញារបស់ព្រះរាជាណាចក្រកម្ពុជាលើការគោរពសិទ្ធិមនុស្ស

## I. សេចក្តីផ្តើមនិងសេចក្តីសង្ខេប

1. យោងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិលេខ៥/១ ដែលអនុញ្ញាតអោយ សង្គមស៊ីវិលចូលរួមក្នុងដំណើរការការត្រួតពិនិត្យជាសកលតាមពេលកំណត់(UPR) យើងជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាល (NGOs) [1] ដោយមានការសម្របសម្រួលពីសម្ព័ន្ធភាពដើម្បីសេរីភាពបញ្ចេញមតិនៅកម្ពុជា(AFEC) និងមជ្ឈមណ្ឌលផ្នែកច្បាប់អាស៊ី (ALRC) បានរៀបចំរបាយការណ៍រួមស្តីពីសេរីភាពបញ្ចេញមតិនិងការជួបប្រជុំនៅកម្ពុជា ដើម្បីដាក់ជូនទៅការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំទីក្រុងហ្សឺណែវ សំរាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍សង្ខេបរបស់ខ្លួនស្តីអំពីពត៌មានដែលបានមកពីស្ថាប័នពាក់ព័ន្ធ។
2. ប្រទេសកម្ពុជា មានកាតព្វកិច្ចសិទ្ធិមនុស្សជាច្រើនក្នុងការគោរពសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ។ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមពាក់ព័ន្ធនឹងយន្តការសិទ្ធិមនុស្សអន្តរជាតិមួយចំនួនក្នុងខណៈពេលដែលហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្សថ្នាក់ជាតិ ក្នុងពេលបច្ចុប្បន្ននៅមានចន្លោះប្រហោងជាច្រើន។ ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ សេរីភាពបញ្ចេញមតិនិងការជួបប្រជុំត្រូវរងនឹងការរឹតបន្តឹងយ៉ាងខ្លាំង រួមមានការរឹតត្បិតខាងការបញ្ចេញមតិ ការបំបិទសំលេងរបស់អ្នកតំណាងរាស្ត្រ ការត្រួតពិនិត្យលើប្រព័ន្ធផ្សព្វផ្សាយ ការទទួលបានពត៌មានត្រូវបានគេទប់ស្កាត់ ហើយការជួបប្រជុំនិងបាតុកម្មតាមទីសាធារណៈត្រូវបានហាមឃាត់។ រាជរដ្ឋាភិបាលបានរំលោភលើកាតព្វកិច្ចអន្តរជាតិនិងនិងរដ្ឋធម្មនុញ្ញដែលមានចែងអំពីសិទ្ធិមនុស្ស និងប្រើប្រាស់នូវរាល់ច្បាប់ជាតិទាំងឡាយដែលផ្ទុយនឹងកាតព្វកិច្ចទាំងនេះ។ ដើម្បីធ្វើឲ្យស្ថានភាពសេរីភាពបញ្ចេញមតិនិងការជួបប្រជុំនេះមានភាពប្រសើរឡើង យើងមានអនុសាសន៍មួយចំនួនដែលរួមមាន៖ ការផ្តល់សច្ចាប័នលើពិធីសារ

---

[1] សម្ព័ន្ធអង្គការនេះរួមមានអង្គការក្រៅរដ្ឋាភិបាលដូចតទៅ ៖ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API) មជ្ឈមណ្ឌលផ្នែកច្បាប់អាស៊ី (ALRC) សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) សមាគមកម្ពុជាដើម្បីការពារអ្នកសារពត៌មាន(CAPJ) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) សមាគមមន្ត្រីរាជការឯករាជ្យ (CICA) សម្ព័ន្ធជំរឿនការពារសិទ្ធិមនុស្សលីការដូ (LICADHO) មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) មជ្ឈមណ្ឌលដើម្បីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (CCPR) សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C-CAWDU) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (COMFREL) មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC) សមាគមប្រជាធិបតេយ្យឯករាជ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) សមាគមខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRA) ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) គណៈកម្មាធិការអព្យាក្រិតនិងមិនលំអៀងសំរាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា(NECFEC) មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍(PDP-Center) អង្គការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ(PADV) សម្ព័ន្ធសារពត៌មានអាស៊ីអគ្នេយ៍ (SEAPA) និងស្តារកម្ពុជា (Star Kampuchea)។ សូមមើលឧបសម្ព័ន្ធ១ ចំពោះអាស័យដ្ឋានរបស់អង្គការទាំងនេះ។

តាមចិត្តជ្រើសរើសទី១ជាប់នឹងកតិការសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ការបង្កើតឲ្យមានស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ និងកំណែទម្រង់ច្បាប់មួយចំនួន។ យើងសូមស្នើឲ្យមានការកសាងសមត្ថភាព និងជំនួយផ្នែកបច្ចេកទេស ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការទទួលយកអនុសាសន៍របស់យើង និងគោរពដល់សេរីភាពបញ្ចេញមតិ និងការជួបប្រជុំ។

## II. ចំនិសាស្ត្រនៃការត្រួតពិនិត្យជាសកលតាមពេលកំណត់ (UPR) និងដំណើរការចែករំលែកពិភាក្សា

3. ដើម្បីរៀបចំរបាយការណ៍រួមនេះ យើងបានធ្វើការជាមួយអង្គការជាតិនិងអន្តរជាតិដើម្បីចែករំលែក និងវិភាគទិន្នន័យតាមរយៈការឃ្លាំមើល ស្រាវជ្រាវ និងការស៊ើបអង្កេត និងជួបជាប្រចាំក្នុងការពិភាក្សាលើខ្លឹមសាររបាយការណ៍នេះ។ យើងនឹងបង្កើតក្រុមការងារក្នុងការសរសេររបាយការណ៍រួមនេះឡើង ដើម្បីជំរុញការយល់ដឹងអំពីដំណើរនៃការត្រួតពិនិត្យជាសកលតាមពេលកំណត់នេះ បញ្ចុះបញ្ចូលឲ្យសហគមន៍អន្តរជាតិជួយគាំទ្រដល់អនុសាសន៍របស់យើង ទាក់ទងជាមួយនឹងរដ្ឋាភិបាល ដើម្បីជួយគាំទ្រ ធ្វើការឃ្លាំមើលលើការអនុវត្តអនុសាសន៍ទាំងនោះ និងការរៀបចំសំរាប់ការត្រួតពីនិត្យ(UPR)លើកក្រោយទៀតលើរបាយការណ៍សិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។
4. រដ្ឋាភិបាល មិនបានយកចិត្តទុកដាក់ទៅលើស្មារតីនៃការត្រួតពិនិត្យជាសកលតាមពេលកំណត់ដែលចង់ឲ្យមានការសហការគ្នា ដោយហេតុថារដ្ឋាភិបាលមិនបានពាក់ពន្ធ័នឹងអង្គការក្រៅរដ្ឋាភិបាល។ យើងទទួលស្គាល់ថា ការខកខាននេះពាក់ពន្ធ័នឹងការខ្វះខាតសមត្ថភាព តែយើងសូមទទូចឲ្យរដ្ឋាភិបាលចូលរួមពាក់ពន្ធ័ជាមួយនឹងសង្គមស៊ីវិល ដើម្បីធានាឲ្យការត្រួតពិនិត្យជាសកលតាមពេលកំណត់ (UPR)មានប្រយោជន៍។ យើងបានផ្ញើរឯកសាររបាយការណ៍នេះទៅរដ្ឋាភិបាល។ [2]

## III. សាវតា និង ក្របខ័ណ្ឌគតយុត្ត

5. ប្រទេសកម្ពុជាទើបចេញពីសង្គ្រាមស៊ីវិលអស់រយៈពេល២០ឆ្នាំ ដែលបន្សល់ពីរបបកម្ពុជាប្រជាធិបតេយ្យ។ សេរីភាពបញ្ចេញមតិ និងការជួបប្រជុំមិនត្រឹមតែសំខាន់សំរាប់សេចក្តីថ្លៃថ្នូរបស់បុគ្គលម្នាក់ៗប៉ុណ្ណោះទេ។ យើងថែមទាំងត្រូវការសិទ្ធិទាំងនេះក្នុងការសំរេចចិត្ត ការទទួលខុសត្រូវខ្ពស់ និងលទ្ធិប្រជាធិបតេយ្យដើម្បីកសាងប្រទេសរបស់យើង។ ប្រជាជនកម្ពុជាមិនអាចចូលរួមក្នុងការសំរេចចិត្តជាសាធារណៈបានទេ ប្រសិនបើពួកគេមិនអាចបញ្ចេញគំនិតរបស់ខ្លួនបានដោយសេរីនិងទទួលបានពត៌មានដោយសេរី និងមិនអាចជួបប្រជុំគ្នាដើម្បីលើកពីបញ្ហាកង្វល់រួម ដើម្បីឲ្យមានឥទ្ធិពលលើរដ្ឋាភិបាលបាននោះទេ។

### ក. វិសាលភាពនៃកាតព្វកិច្ចអន្តរជាតិ

6. ក្នុងនាមជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាក្រោមធម្មនុញ្ញនៃអង្គការសហប្រជាជាតិមានកាតព្វកិច្ចគោរពសិទ្ធិមនុស្សជាសកល។ ធម្មនុញ្ញនៃអង្គការសហប្រជាជាតិបានចែងថា ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ហើយនិងការ

---

[2] យើងបានផ្ញើរឯកសាររបាយការណ៍នេះទៅគណៈកម្មការសិទ្ធិមនុស្សនិងទទួលពាក្យបណ្ដឹងនៃរដ្ឋសភា និងព្រឹទ្ធិសភា និងគណៈកម្មការសិទ្ធិមនុស្សកម្ពុជារបស់របស់រដ្ឋាភិបាល។

ទទួលស្គាល់សិទ្ធិស្មើភាពគ្នានឹងមិនអាចលក់ដូរ ផ្ទេរ ឬ ដកហូតបានជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

7. មាត្រា១៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយរួមគ្នានៃជំលោះកម្ពុជាបានចែងថា *"មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា...ត្រូវមានសិទ្ធិនិងសេរីភាពដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបណ្តាកិច្ចព្រមព្រៀងអន្តរ ជាតិទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។"* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR) បានអនុម័តនិងប្រកាសដោយសេចក្តីសម្រេចចិត្តនៃមហាសន្និបាតអង្គការសហ ប្រជាជាតិហើយផ្តល់ជាស្តង់ដាសិទ្ធិមនុស្ស ដែលទទួលស្គាល់ដោយរដ្ឋជាសមាជិកទាំងអស់។ មាត្រាទី១៩ បានចែងថាអំពី *"សិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែកនិងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយពត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"* មាត្រាទី ២០ ស្តីពីការការពារសិទ្ធិសេរីភាពនៃការប្រជុំ។ ភាគច្រើននៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនោះ ត្រូវគេគិតថា ទទួលបាននូវអំណាចខាងផ្លូវច្បាប់ជាច្បាប់អន្តរជាតិបែបប្រពៃណី ហើយកម្ពុជាបានយល់ព្រមអនុម័តតាមដែលជាផ្នែកមួយនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[3]

8. *"លិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត"* ដែលកិច្ចព្រមព្រៀងទីក្រុងប៉ារីសសំដៅទៅលើនោះគឺរួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) ដែលចូលជាធរមាននៅប្រទេសកម្ពុជាឆ្នាំ១៩៩២។ កតិកាសញ្ញានេះមានអំណាចបង្ខំឲ្យរដ្ឋអនុម័តតាមដោយផ្ទាល់ជាផ្លូវការនិងមានខ្លឹមសារលំអិត បន្ថែមទៅលើសេចក្តីប្រកាសជាំសកលស្តីពីសិទ្ធិមនុស្ស (UDHR)។ មាត្រា១៩ ចែងថា *"ជនគ្រប់រូបមានសិទ្ធិក្នុងការប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។ ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្វែងរកពត៌មាន ទទួល និងផ្សព្វផ្សាយពត៌មាននិង គំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន...*។ ប៉ុន្តែ មាត្រានេះក៏បាននិយាយផងដែរពីការរឹតបន្តឹងលើការប្រើប្រាស់សិទ្ធិទាំងនេះ *"គោរពសិទ្ធិ និងកិត្តិស័ព្ទរបស់អ្នកដទៃ... ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពឬសិលធម៌សាធារណៈ។"* មាត្រាទី២១ ចែងថា *"សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ ការការពារសុខភាពសាធារណៈឬ សីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។"*

9. គោលការណ៍ណែនាំបន្ថែមទៀតលើការបកស្រាយមាត្រាទី១៩របស់ ICCPR អាចឃើញមានយ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសដែលធ្វើឡើងដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិលើការលើកស្ទួយ និងការពារលើសិទ្ធិសេរីភាពក្នុងការមានមតិ និងបញ្ចេញមតិ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិព្យាយាមបកស្រាយពីអត្ថន័យនៃសិទ្ធិសេរីភាពបញ្ចេញមតិ។ កាន់តែសំខាន់ជាងនេះទៅទៀត អ្នករាយការណ៍ពិសេសរបស់អង្គការ

[3] មាត្រាទី១៩ "អនុស្សារណៈស្តីពីច្បាប់ស្តីពីសារពត៌មានកម្ពុជា" ឡុងដុង ខែតុលាឆ្នាំ ២០០៤។ សូមមើលក្នុងឧបសម្ព័ន២ នៅក្នុងរបាយការណ៍រួមនេះ។

សហប្រជាជាតិបានគាំទ្រក្នុងរបាយការណ៍របស់គាត់នៅឆ្នាំ១៩៩៦ [4] ដោយបានទទួលស្គាល់លើគោលការណ៍ទីក្រុងជហាននេសបឺក (Jahannesburg) ស្តីពី**សន្តិសុខសង្គម សេរីភាពបញ្ចេញមតិ និងការទទួលបានពត៌មាន** (១៩៩៦) (the Johannesburg Principles)។ គោលការណ៍ជហាននេសបឺក ជាគោលការណ៍កំរិតវិសាលភាពលើការរឹតត្បិតសេរីភាពបញ្ចេញមតិ។

10. គោលការណ៍ច្បាប់អន្តរជាតិនៅក្នុងតុលាការ ស្តីអំពីលិខិតូបករណ៍សិទ្ធិមនុស្សថ្នាក់តំបន់បី (អឺរុប អាហ្វ្រិក និងអាមេរិក) បានសង្កត់ធ្ងន់ជាហូរហែរលើសារៈសំខាន់នៃសេរីភាពបញ្ចេញមតិនិងជួបប្រជុំ ដែលនាំអាយមានការបកស្រាយចង្អៀតលើទំហំផ្នែកច្បាប់នៃការរិតត្បិត និងការដាក់ពិន័យ។

## ខ. រដ្ឋធម្មនុញ្ញ និងក្រមខណ្ឌច្បាប់

11. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលមានចែងនៅក្នុងមាត្រាទី៣១ ថា *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសកជាសកលស្តីពីសិទ្ធិមនុស្សនិងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស..."*។ មាត្រាទី៤១ ចែងថា *"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កត្តិយសអ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិបានឡើយ។ របបសាពត៌មានត្រូវរៀបចំដោយច្បាប់។* មាត្រា៣៧ ចែងពី *"សិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់ "*។ យោងតាមសេចក្តីសំរេចពីក្រុមប្រឹក្សារដ្ឋធម្មនុញ្ញកម្ពុជាដែលចុះនៅថ្ងៃទី១០ ខែកក្កដា២០០៧ ថា រាល់លិខិតូបករណ៍សិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានគោរពតាមជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញ។"

## គ. ស្ថាប័ន និងហេដ្ឋារចនាសម្ព័នសិទ្ធិមនុស្ស

12. ក្នុងនាមជារដ្ឋភាគីក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ កម្ពុជាមានកាតព្វកិច្ចរាយការណ៍ជូនទៅស្ថាបន័សន្ធិសញ្ញាធ្វើការពិនិត្យលើអនុសញ្ញានេះ ដែលមានឈ្មោះថា "គណៈកម្មការសិទ្ធិមនុស្ស"។ របាយការណ៍លើកទី២របស់កម្ពុជាបានហួសកំណត់តាំងពីថ្ងៃ៣១ ខែកក្កដា ឆ្នាំ២០០២។ យើងកត់សំគាល់ឃើញថា ប្រទេសកម្ពុជាបានចុះហត្ថលេខាលើពិធីសារជំរើសលើកដំបូងលើICCPR នៅថ្ងៃ២៧ ខែកញ្ញា ឆ្នាំ២០០៤ ប៉ុន្តែកម្ពុជាមិនបានផ្តល់សច្ចាប័នលើពិធីសារនេះទេ ដែលជាហេតុធ្វើឲ្យពិធីសារនេះមិនមានអំណាចបង្ខំឲ្យរដ្ឋអនុវត្តតាមដោយផ្ទាល់បាន។

13. យើងស្វាគមន៍ចំពោះរូបភាពពិតជាក់ស្តែង ដែលថាប្រទេសកម្ពុជាបានអនុញ្ញាតឲ្យមានការិយាល័យឧត្តមស្នងការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស(OHCHR)ប្រចាំនៅកម្ពុជា ដែលដើរតួរយ៉ាងសំខាន់ក្នុងការឃ្លាំមើលស្ថានភាពសិទ្ធិមនុស្ស។ ប្រទេសកម្ពុជាក៏បានទទួលផលប្រយោជន៍ពីអណត្តិរបស់តំណាងពិសេសរបស់អគ្គលេខាធិការខាងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាមួយចំនួនផងដែរ តាមរយៈការទទួលបាននូវការវាយតម្លៃដ៏មានតំលៃ និងអនុសាសន៍ល្អៗសំរាប់ធ្វើឲ្យប្រសើរនូវស្ថានភាព

---

[4] របាយការណ៍ស្តីពីអ្នករាយការណ៍ពិសេស យើងតាមសេចក្តីសំរេចគណៈកម្មាធិការសិទ្ធិមនុស្ស១៩៩៣/45ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម ២២ មិនា ១៩៩៦។

សិទ្ធិមនុស្សនៅកម្ពុជា។ ប៉ុន្តែជាអកុសល ឋានៈ"តំណាងពិសេស"នោះបានបន្ថយមកនៅត្រឹមតែជា "អ្នករាយការណ៍ពិសេស"ទៅវិញ។

14. នៅក្នុងប្រទេសកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នកំពូល ដែលតាមរយៈស្ថាប័ននេះពលរដ្ឋម្នាក់ៗអាចមានធ្វើការតវ៉ាអំពីធម្មនុញ្ញភាពនៃច្បាប់ បទបញ្ញា និងការសំរេចរបស់រដ្ឋដែលប៉ះពាល់ដល់សិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែនិតិវិធីដែលពាក់ពន្ធ័នឹងការតវ៉ានេះបានរារាំងប្រជាពលរដ្ឋមិនឲ្យជួបផ្ទាល់ជាមួយនឹងក្រុមប្រឹក្សា។ ប្រជាពលរដ្ឋម្នាក់ដែលមានបំណងចង់ដាក់ពាក្យបណ្តឹងត្រូវទៅដល់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា ១ភាគ១០ នៃតំណាងរាស្ត្រ រឺក៏ ១ភាគ៤នៃសមាជិកព្រឹទ្ធិសភាដើម្បីសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការវិនិច្ឆ័យរឿងក្តីនេះ។ ជាងនេះទៅទៀត ក្រុមប្រឹក្សាធម្មនុញ្ញមិនឯករាជ្យពីរដ្ឋាភិបាលឡើយ។[5]

15. មាត្រាទី១៤៧ដល់១៤៩ នៃរដ្ឋធម្មនុញ្ញមានចែងពីការប្រជុំសមាជជាតិប្រចាំឆ្នាំដែលជាផ្នែកមួយនៃលទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ *"ដែលប្រជាជនកម្ពុជាមានឱកាសជួបជាមួយនឹងមេដឹកនាំផ្ទាល់។ សមាជជាតិបើកឲ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិនិងលើកបញ្ហានិងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ។"* ប៉ុន្តែជាអកុសលសមាជជាតិនេះមិនដែលបានជួបប្រជុំទេ ហើយកាលពីថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៩ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថាសមាជជាតិនេះគួរតែលុបចេញពីរដ្ឋធម្មនុញ្ញទៀតផង។

16. ស្ថាបន័រដ្ឋបីផ្សេងទៀតមានតួនាទីក្នុងការការពារសិទ្ធិមនុស្ស។ រដ្ឋសភាជាតិ និងព្រឹទ្ធិសភាមានគណៈកម្មការសិទ្ធិមនុស្សនិងទទួលពាក្យបណ្តឹងរៀងៗខ្លួន និងរដ្ឋាភិបាលមានគណៈកម្មការរបស់ខ្លួនផងដែរហៅថា"គណៈកម្មការសិទ្ធិមនុស្សកម្ពុជា"។ ស្ថាប័នទាំងនេះអាចធ្វើការស៊ើបអង្កេត តែបរាជ័យក្នុងការការពារនិងដោះស្រាយបញ្ហាដល់ជនរងគ្រោះ រឺក៏នាំជនប្រព្រឹត្តមកផ្តន្ទាទោស។ ស្ថាប័នទាំងនេះត្រូវបានគេចាត់ទុកថាជា ស្ថាប័នដែលស្ថិតនៅក្រោមអំណាចនយោបាយយ៉ាងខ្លាំង។[6] នៅខែកញ្ញា ឆ្នាំ២០០៦ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសផែនការក្នុងការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សជាតិ ដោយផ្អែកលើ *"គោលការណ៍នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស"*។ គោលការណ៍ទីក្រុងប៉ារីសទាក់ទងនឹងឋានៈនិងតួនាទីនៃស្ថាប័នថ្នាក់ជាតិឯករាជ្យដើម្បីការការពារ និងលើកស្ទួយដល់ការគោរពសិទ្ធិមនុស្ស។[7] ថ្មីៗនេះប្រទេសកម្ពុជាគ្មានផែនការសកម្មភាពថ្នាក់ជាតិ ឬគោលនយោបាយសំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សទេ។

17. មានរបាយណ៍ជាច្រើនបង្ហាញថា តុលាការកម្ពុជាមិនមានសមត្ថភាព ពោរពេញដោយអំពើរពុករលួយ និងស្ថិតក្រោមអំណាចនយោបាយ។[8] នាពេលបច្ចុប្បន្ន ការចោទប្រកាន់ស្រដៀងគ្នានេះកំពុងតែគំរាមកំហែងដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការខ្មែរក្រហម) (ECCC) ។

---

[5] កម្ពុជា ៖ អជ្ញាធរត្រូវផ្តល់សច្ចាប័នលើពិធីសារលើកទី១ ជាប់នឹងICCPR ក្នុងពេលបច្ចុប្បន្ននេះ។ AHRC ថ្ងៃទី ២២ មិនា ២០០៦។

[6] ដដែល។

[7] គោលការណ៍កិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានកំណត់ជាសប្បសាលាអន្តរជាតិដំបូងគេស្តីពីស្ថាប័នជាតិក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅទីក្រុងប៉ារីសនៅខែតុលាឆ្នាំ ១៩៩១។

[8] សិទ្ធិមនុស្សនៅកម្ពុជា៖ របាយការណ៍យុត្តិធម៌ ២០០៧ ដោយ LICADHO ភ្នំពេញ ២០០៧។

18. នៅក្នុងប្រទេសកម្ពុជាមានអង្គការសង្គមស៊ីវិលច្រើន ដែលបានគាំទ្រដោយម្ចាស់ជំនួយអន្តរជាតិ ហើយអង្គការទាំងនេះបានទាក់ទាញចំណាប់អារម្មណ៍ជាច្រើន។ ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលប្រឈមមុខនឹងការយាយីជាបន្តបន្ទាប់ពីរដ្ឋាភិបាល ដូចមានបង្ហាញនៅក្នុងរបាយការណ៍នេះ។ ជាងនេះទៅទៀត អង្គការទាំងនេះប្រឈមនឹងរាជរដ្ឋាភិបាលអណត្តិថ្មីដែលប៉ុនប៉ងគ្រប់គ្រងអង្គការខ្លួនតាមរយៈច្បាប់ស្តីពីអង្គការសមាគមន៍ ដែលទើបចេញជាសេចក្តីព្រាងនៅឡើយ។ សេចក្តីព្រាងច្បាប់អង្គការសមាគមន៍ ផ្តល់អំណាចឲ្យរដ្ឋាភិបាលគ្រប់គ្រងដល់ហិរញ្ញវត្ថុរបស់អង្គការក្រៅរដ្ឋាភិបាល និងនាំឲ្យមានភាពសុាំញ៉ាំលើការចុះបញ្ជីរច្បាប់ច្រើន និងមិនឲ្យអង្គការក្រៅរដ្ឋាភិបាលមានសកម្មភាពផ្នែកនយោបាយណាមួយ ។

## IV. ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា

19. រដ្ឋាភិបាលគួរតែទទួលបាននូវការសសើរ ក្នុងការចុះហត្ថលេខាលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ (និងឆ្នាំថ្មីមុនៗទៀត) គេកត់សំគាល់ឃើញថា រដ្ឋាភិបាលបរាជ័យមិនបានសហការជាមួយនឹងយន្តការសិទ្ធិមនុស្ស និងបានរឹតបន្តឹងសិទ្ធិមនុស្សរួមទាំងសេរីភាពបញ្ចេញមតិ និងការជួបប្រជុំផង។

### ក. កិច្ចសហប្រតិបត្តិការជាមួយនឹងយន្តការសិទ្ធិមនុស្ស

20. ប្រទេសកម្ពុជាមិនបានផ្តល់របាយការណ៍លើកទី២ដល់គណៈកម្មាធិការសិទ្ធិមនុស្ស និងបរាជ័យមិនបានបញ្ជូនរបាយការណ៍តាមរយៈកាលទៅស្ថាប័នសន្ធិសញ្ញាដទៃទៀតដែរ។ ប៉ុន្តែយើងពិតជាកត់សំគាល់ថា រដ្ឋាភិបាលកំពុងធ្វើការជាមួយនឹងការិយាល័យឧត្តមស្នងការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីធ្វើឲ្យស្ថានភាពនេះកាន់តែប្រសើរឡើង។ ទោះបីចុះហត្ថលេខាលើពិធីសារតាមចិត្តជ្រើសរើសទី១ជាប់នឹងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅថ្ងៃ២៧ ខែកញ្ញា ឆ្នាំ២០០៤ ក៏ដោយ ក៏កម្ពុជាបរាជ័យក្នុងការផ្តល់សច្ចាប័នលើលិខិតូបករណ៍នេះដែរ។ ជាងនេះទៅទៀត ខណៈដែលកម្ពុជាបន្តទទួលឲ្យមានការតាំងនៅនៃការិយាល័យឧត្តមស្នងការ អាកប្បកិរិយារបស់េដ្ឋាភិបាលចំពោះអ្នករាយការណ៍ពិសេស របស់អគ្គលេខាធិការស្តីពីសិទ្ធិមនុស្សនៅកម្ពុជាដូចជាលោក យ៉ាស ហ្គាយ (Yash Ghai) ជារឿងដែលគួរឲ្យព្រួយបារម្ភ។ រដ្ឋាភិបាលក៏បានផ្តល់ការយកចិត្តទុកដាក់តិចតួចបំផុតដល់អង្គការអន្តរជាតិ។

21. ក្នុងថ្នាក់តំបន់ មាត្រាទី១៤នៃធម្មនុញ្ញអាស៊ានតំរូវឲ្យមានការបង្កើតស្ថាប័នសិទ្ធិមនុស្សអាស៊ានដែលនឹងជួយការពារ និងលើកស្ទួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ក្នុងន័យនេះ យើងស្វាគមន៍ចំពោះការពាក់ព័ន្ធរបស់កម្ពុជាក្នុងការចរចារ និងការចូលរួមជាមួយនឹងសង្គមស៊ីវិលក្នុងបញ្ហានេះ។

22. នៅថ្នាក់ជាតិវិញ រដ្ឋាភិបាលគ្រប់គ្រងលើស្ថាប័នសិទ្ធិមនុស្សទាំងបី។ ប៉ុន្តែយើងពិតជាទទួលស្គាល់កិច្ចប្រឹងប្រែងថ្មីៗក្នុងការពាក់ព័ន្ធសហគមន៍ក្នុងស្រុក ហើយសង្ឃឹមថាការសន្យារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ថានឹងបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សជាតិនឹងលេចចេញជារូបរាងពិតនៅឆ្នាំ២០០៩។ ខណៈដែលរដ្ឋាភិបាលកំពុងរៀបចំផែនការដើម្បីជំរុញតាមរយៈច្បាប់ស្តីពីអង្គការសមាគមន៍ យើងទទួលស្គាល់ថា ទំនាក់ទំនងការងារជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលបានកើនឡើង ហើយសង្ឃឹមថាទំនាក់ទំនងនេះនឹងបន្តឲ្យកាន់តែមានភាពជិតដិតឡើងថែមទៀត។

### ខ. ការអនុវត្តន៍កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ

23. សេរីភាពបញ្ចេញមតិ និងការជួបជុំនៅកម្ពុជាក្នុងរយៈកាល៥ឆ្នាំចុងក្រោយនេះ ត្រូវបានគេរំលោភជាញឹកញាប់ ដោយមើលឃើញតាមរយៈការមិនអើពើនឹងកាតព្វកិច្ចសិទ្ធិមនុស្សជាតិ និងអន្តរជាតិ។ ការរំលោភទាំងនេះត្រូវបានគាំទ្រដោយច្បាប់ជាតិ ដែលផ្ទុយនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា។

### *១) ការរឹតបន្តឹងលើការបញ្ចេញមតិ*

24. ប្រជាពលរដ្ឋកម្ពុជាមិនបានទទួលនូវសិទ្ធិសេរីភាពពេញលេញ ក្នុងការបញ្ចេញមតិរបស់ខ្លួនដែលផ្ទុយនឹងរដ្ឋាភិបាលឡើយ។ រដ្ឋាភិបាលបានប្រើអំណាចច្បាប់ខាងបទល្មើសផ្សាយពត៌មានមិនពិត បរិហារកេរ្តិ៍ និងបទញុះញង់ ក្នុងច្បាប់ព្រហ្មទណ្ឌដើម្បីរឹតបន្តឹងលើការបញ្ចេញមតិពាក់ព័ន្ធនឹងបញ្ហារសើប ដូចជាបញ្ហាព្រំដែន អំពើពុករលួយ និងការរំលោភដីធ្លី និងបញ្ហារសើបដទៃទៀត ។

- ចាប់ពីខែតុលា ដល់ខែកញ្ញា ឆ្នាំ២០០៥ អ្នកគាំទ្រសិទ្ធិមនុស្សដ៏ល្បីល្បាញ៨ នាក់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនពីបទផ្សាយពត៌មិនពិត បរិហារកេរ្តិ៍ រឺ/និងបទញុះញង់។ លោក ម៉ម សូណង់ដូរ ជាម្ចាស់និងជាប្រធានស្ថានីយវិទ្យុសំបុកឃ្មុំឯករាជ្យត្រូវបានចាប់ខ្លួនពីបទចាក់ផ្សាយបទសំភាសជាមួយនឹងសកម្មជនខ្មែរ នៅបារាំង ដែលរិះគន់លើសន្ធិសញ្ញាព្រំដែនកម្ពុជាវៀតណាម។ លោក រ៉ុង ឈុន ជាប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា ត្រូវបានចាប់ខ្លួនដោយសារការចេញសេចក្តីថ្លែងការណ៍ទាក់ទងនឹងសន្ធិសញ្ញាព្រំដែន។ លោក ម៉ែន ណាត ជាប្រធានសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា និង លោក អៀ ចាន់ណា ជាអគ្គលេខាធិការរងនៃចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍នេះដែរបានរត់គេចខ្លួនទៅប្រទេសថៃ ហើយឥឡូវនេះអ្នកទាំងពីរកំពុងរស់នៅអឺរ៉ុប។ លោក កឹម សុខា ជាអតីតប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវចាប់ខ្លួនទាក់ទងនឹងផ្ទាំងប៉ាណូរបស់មជ្ឈមណ្ឌលក្នុងថ្ងៃប្រារព្ធទិវាសិទ្ធិមនុស្ស១០ធ្នូ។ នៅលើផ្ទាំងនោះមានសរសេរអក្សរតូចៗ ដោយអ្នកភូមិដែលបញ្ចេញមតិទាក់ទងនឹងនយោបាយ។ ការសរសេរមួយនោះគឺរិះគន់ដោយចោទប្រកាន់លោក ហ៊ុន សែន និងចោទថាដីខ្មែរត្រូវបាត់បង់ទៅឲ្យវៀតណាម។ លោក យ៉េង វីរៈ ជានាយកប្រតិបត្តិរបស់មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ ត្រូវបានចាប់ខ្លួន៩ថ្ងៃមុនការចាប់ខ្លួនរបស់ លោក ប៉ា ងួនទៀង ដែលពេលនោះជាប្រធានខាងផ្នែកវិទ្យុរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ បន្ទាប់ពីមានសម្ពាធពីសហគមន៍ជាតិនិងអន្តរជាតិ អ្នកដែលជាប់ឃុំខាងលើត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។
- នៅខែកញ្ញា ឆ្នាំ២០០៦ លោក ទៀង ណារិទ្ធិ ជាគ្រូបង្រៀនខាងច្បាប់និងនយោបាយនៅពុទ្ធិកមហាវិទ្យាល័យព្រះស៊ីហានុនៅក្នុងទីក្រុងភ្នំពេញ ត្រូវបានបណ្តេញចេញពីតួនាទីដោយសារការសរសេរសៀវភៅរិះគន់ដល់រដ្ឋាភិបាល។ បន្ទាប់មកគាត់ត្រូវចាប់ខ្លួននិងចោទប្រកាន់ពីបទផ្សាយពត៌មានមិនពិត និងត្រូវកាត់ទោសមានកំហុស និងជាប់គុករយៈពេលជាងពីរឆ្នាំ និងផាកពិន័យ។ គាត់ទើបត្រូវបានគេដោះលែងនាពេលថ្មីៗនេះ និងទទួលរងការចោទប្រកាន់ថាមានជំងឺវិកលចរិត។

- របាយការណ៍ដែលចេញដោយអង្គការឃ្លាំមើលសកលលោក (Global Witness) ដែលនិយាយពីការពាក់ពន្ធ័របស់មន្រ្តីជាន់ខ្ពស់ និងញាតិសន្តានរបស់ពួកគេក្នុងការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅកម្ពុជាត្រូវបានហាមមិនឲ្យចែកផ្សាយកាលពីខែមិថុនាឆ្នាំ ២០០៧។
- នៅឆ្នាំ២០០៩ ចៅក្រមជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានគំរាម លោក មេធាវី មីសែល ផែសមែន (Michiel Pestman) និង លោក អែនឌ្រូ ឡានូស្ស៊ី (Andrew Lanuzzi) ដែលជាអ្នកការពារក្តីឲ្យលោក នួន ជា ថានឹងទទួលការចាត់វិធានការណ៍ផ្លូវច្បាប់ បន្ទាប់ពីពួកគាត់បានស្នើរតុលាការជាតិធ្វើការស៊ើបអង្កេតពីអំពើពុករលួយ។ មេធាវីមិនត្រូវបានលើកទឹកចិត្ត ក្នុងការបញ្ចេញមតិបន្ទោសបង្អាប់ចំពោះស្ថានភាពបច្ចុប្បន្នទេ ទោះបីនៅថ្នាក់តុលាការឧក្រិដ្ឋអន្តរជាតិក្ខនកាត់នេះក៏ដោយ។

25. ករណីខាងលើនេះ គឺគ្រាន់តែជាឧទាហរណ៍មួយចំនួនក្នុងចំណោមឧទាហរណ៍ជាច្រើនដែលបង្ហាញពីអំពើរបស់រដ្ឋាភិបាល ក្នុងការរឹតបន្តឹងលើសេរីភាពបញ្ចេញមតិ ដែលរំលោភលើសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និង មាត្រាទី១៩ របស់ ICCPR និងមាត្រាទី៣១ និង៤១ នៃរដ្ឋធម្មនុញ្ញ។

26. ជាងនេះទៅទៀត ច្បាប់ដែលប្រើ រឺក៏ករណីគំរាមទាំងនេះ រួមមានបទញុះញង់ បទបរិហាកេរ្តិ៍ និងផ្សាយពត៌មានមិនពិតជាដើមនោះ បានរំលោភលើកាតព្វកិច្ចអន្តរជាតិ និងរដ្ឋធម្មនុញ្ញ។ មាត្រា ៦២ នៅក្នុងច្បាប់អ៊ុនតាក់និយាយពីបទព្រហ្មទណ្ឌក្នុងការផ្សាយពត៌មានមិនពិតថា *"ពេលណាមានការចុះផ្សាយ ការផ្សព្វផ្សាយ ឬការផ្សាយបន្តតាមមធ្យោបាយណាក៏ដោយនូវពត៌មានមិនពិត ពត៌មានប្រឌិត ពត៌មានក្លែងក្លាយ ឬដោយកុហក ទំលាក់កំហុសដោយអសុទ្ធចិត្តទៅលើជនទីបីក្នុងបំណងបំផ្លិចបំផ្លាញ ធ្វើឲ្យកើតកោលាហលដល់សន្តិសុខសាធារណៈឬអាចបណ្តាលឲ្យកើតកោលាហលដល់សន្តិសុខសាធារណៈ នាយក ឬអ្នកទទួលខុសត្រូវផ្សេងទៀតនៃការផ្សាយ ឬអ្នកទទួលខុសត្រូវលើមធ្យោបាយគមនាគមន៍ឯទៀតដែលពាក់ពន្ធ័ ដែលបានសំរេចទទួលចុះផ្សាយ ផ្សព្វផ្សាយ ឬ ផ្សាយបន្តនូវពត៌មានទាំងនោះនឹងត្រូវផន្តាទោសដាក់គុកពី៦ ខែទៅ៣ឆ្នាំ ហើយត្រូវដាកពិន័យជាប្រាក់ពី១ ០០០ ០០០ ទៅ ១០ ០០០ ០០០ រៀល ឬ ផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន។"* មាត្រាទី៦៣ នៃច្បាប់នេះដដែលទាក់ទងនឹងបទបរិហារកេរ្តិ៍ចែងថា *"ការបរិហារកេរ្តិ៍ ឬការជេរប្រមាថប្រព្រឹត្តិឡើងតាមមធ្យោបាយណាមួយដែលមានចែងក្នុងមាត្រាទី៥៩ នឹងត្រូវផ្តន្ទាទោសដាក់គុកពី៨ថ្ងៃ ទៅ១ឆ្នាំ"*។ ច្បាប់ទាំងនេះបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩២ ក្នុងសម័យអន្តរកាលក្រោមរដ្ឋបាលគ្រប់គ្រងសម័យអ៊ុនតាក់ នៅពេលមានសង្គ្រាមស៊ីវិលនៅកម្ពុជា ។ ច្បាប់ទាំងនេះត្រូវបានប្រើដើម្បីការពារ និងដាក់ទ័ណ្ឌកម្មលើការរិះគន់ដល់អ្នកមានអំណាច។ ច្បាប់នោះផ្ទុយនឹងស្តង់ដារសេរីភាពបញ្ចេញមតិអន្តរជាតិ ហើយបង្កើតឲ្យមានបរិយាកាសភ័យខ្លាចទៀតផង។ នៅក្នុងសេចក្តីប្រកាសរួមនៅក្នុងឆ្នាំ១៩៩៩ ឆ្នាំ២០០០ និងម្តងទៀតនៅឆ្នាំ២០០២ បុគ្គលថ្នាក់អន្តរជាតិពិសេសបីដើម្បីលើកស្ទួយសេរីភាពបញ្ចេញមតិ (រួមមានអ្នករាយការណ៍ពិសេសតំណាងអង្គការសន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុបស្តីពីសេរីភាពនៃប្រពន្ធ័ផ្សព្វផ្សាយ និងអ្នករាយការណ៍ពិសេសOAS លើសេរីភាពបញ្ចេញមតិ) បានអំពាវនាវឲ្យរដ្ឋនានាលុបចោលបទបរិហារកេរ្តិ៍ចេញពីច្បាប់ព្រហ្មទណ្ឌ។ [9] តាមការសង្កេតលើរបាយការណ៍តាមកាលកំណត់របស់ប្រទេសម៉ិច

[9] កំណត់ត្រាសង្ខេបស្តីពីសេចក្តីប្រកាសស្តង់ដារប្រៀបធៀបនិងអន្តរជាតិ មាត្រាទី១៩ ឡុងដុង កុម្ភៈ២០០៤។

សិចក្ដ ក្រុមប្រឹក្សាសិទ្ធិមនុស្សកត់សំគាល់ថា ក្រុមប្រឹក្សារិះគន់យ៉ាងខ្លាំងលើការចាត់ទុកការបរិហាកេរ្តិ៍ជ្ជថាជាបទល្មើស និងអំពាវនាវឲ្យលុបចោលបទចោទនេះ។

27. ឆ្លើយតបនឹងសម្ពាធជាតិនិងអន្តរជាតិ នៅថ្ងៃ២១ ខែមេសា ឆ្នាំ២០០៦ រដ្ឋាភិបាលកម្ពុជាសំរេចលុបចោលការដាក់ទោសជាប់គុកសំរាប់បទបរិហាកេរ្តិ៍។ នៅថ្ងៃ១៣ ខែសីហា ឆ្នាំ២០០៧ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា រដ្ឋាភិបាលកម្ពុជាបានសំរេចលុបចោទបទបរិហារកេរ្តិ៍ពីក្រមព្រហ្មទណ្ឌ។ ប៉ុន្តែ ការសន្យានេះមិនទាន់ក្លាយជាការពិតនៅឡើយទេ។

## ២) ការបំបិទសំលេងរបស់សមាជិកសភា

28. សមាជិកសភា ក៏ឃើញមានការរឹតបណ្តឹងពីសេរីភាពបញ្ចេញមតិរបស់ពួកគាត់ខ្លាំងផងដែរ។ រដ្ឋាភិបាលបានយកច្បាប់ព្រហ្មទណ្ឌមកប្រើ និងវិសោធនកម្មទៅលើបទបញ្ជាផ្ទៃក្នុងរបស់សភាដើម្បីគាបសង្កត់ដល់តំណាងរាស្ត្រមានការភិតភ័យក្នុងការជជែកពិភាក្សា និងតាក់តែងច្បាប់។ នេះជាការរំលោភដល់លទ្ធិប្រជាធិបតេយ្យ។ ជាការពិតណាស់ចំនួនសមាជិកសភាបញ្ចេញមតិនៅក្នុងសភាបានថយចុះក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ។[10]

- នៅថ្ងៃ៣ ខែកុម្ភៈ ឆ្នាំ២០០៥ លោក សម រង្ស៊ី មេដឹកនាំគណៈបក្សប្រឆាំងសមរង្ស៊ី (SRP) បានរត់ភៀសខ្លួនដោយភ័យខ្លាចពីការចាប់ខ្លួន បន្ទាប់ពីសភាបានបោះឆ្នោតដកអភ័យឯកសិទ្ធិពីលោក និងសមាជិកសភាមកពីគណៈបក្សសមរង្ស៊ីមានលោក ជា ប៉ូច និង លោក ជាម ចាន្នី។ នៅថ្ងៃដដែលនោះផងដែរ តំណាងរាស្ត្រ ជាម ចាន្នី ត្រូវចាប់ខ្លួននិងជាប់ឃុំនៅក្នុងពន្ធនាគារយោធាកម្ពុជា។ លោក សម រង្ស៊ី ជាប់ចោទពីបទបរិហារកេរ្តិ៍នៃច្បាប់ព្រហ្មទណ្ឌជាច្រើន បន្ទាប់ពីលោកចោទប្រកាន់គណៈបក្សប្រជាជន គណៈបក្សហ្វុនស៊ិនប៉ិចពីអំពើពុករលួយនៅក្នុងការបង្កើតសម្ព័នភាពរដ្ឋាភិបាលពីមុននិងថ្មីៗនេះ។ គាត់បានចោទនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីបទជាប់ពាក់ព័ន្ធនឹងការសម្លាប់លោក ជា វិជ្ជា ជាអតីតមេដឹកនាំសហជីពសេរីកម្មករ ដែលមានសម្ព័នភាពជាមួយនឹងគណៈបក្សសមរង្ស៊ី។ លោក សម រង្ស៊ី ព្យាយាមអវត្តមាននៅថ្ងៃទី២២ខែធ្នូ ឆ្នាំ២០០៥ តែតុលាការបានកាត់ទោសលោកឲ្យជាប់គុករយៈពេល១៨ខែ និងផាកពិន័យ។ អគ្គរាជទូតអាមេរិកនៅទីក្រុងភ្នំពេញបាននិយាយថា"វាគួរឲ្យព្រួយបារម្ភ ដែលថារដ្ឋាភិបាលកំពុងព្យាយាមធ្វើអោយបក្សប្រឆាំងនៅស្ងៀម។" នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦ លោកសមរង្ស៊ីបានទទួលការលើកលែងទោសពីព្រះមហាក្សត្រព្រះបាទនរោត្តមសីហមុនី តាមការស្នើរសុំពីនាយករដ្ឋមន្ត្រី ហ៊ុន សែន។[11]
- នៅខែកញ្ញា ឆ្នាំ២០០៨ នៅពេលសភាថ្មីស្បថចូលកាន់តំណែង គណៈបក្សប្រជាជនកម្ពុជាប្រើអំណាចគ្របដណ្តប់លើការយកបទបញ្ជាផ្ទៃក្នុងថ្មីមកប្រើ ទោះបីជាមានការមិនយល់ព្រមពីគណៈបក្សសមរង្ស៊ី និងគណៈបក្សសិទ្ធិមនុស្ស។ យោងតាមមាត្រា៤៨ និង៥៥នៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ សមាជិកសភាត្រូវអង្គុយជាក្រុម ហើយក្នុងមួយក្រុមមានយ៉ាងតិច

---

[10] របាយការណ៍ឃ្លាំមើលសភា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ២០០៧

[11] កម្ពុជា បក្សប្រឆាំងស្នើសុំដល់ព្រះមហាក្សត្រ BBC ៤ កុម្ភៈ ២០០៥។

សមាជិក១០នាក់ និងប្រធានក្រុមម្នាក់ និងអនុប្រធានក្រុមម្នាក់។ សមាជិកសភាដែលមកពីគណៈបក្សដែលមានអសនៈតិចជាង១០ ត្រូវចូលរួមក្នុងក្រុមណាមួយ ដែលខ្លួនពេញចិត្ត។ សមាជិកសភាមិនអាចនិយាយក្នុងសភាបានទេ ប្រសិនបើមិនមានការស្នើសុំទៅប្រធានក្រុម និងការអនុញ្ញាតពីប្រធានរដ្ឋសភា។ បទបញ្ជាផ្ទៃក្នុងទាំងនេះមកដល់បច្ចុប្បន្នបានរារាំងសមាជិកសភាបីរូប មកពីគណៈបក្សសិទ្ធិមនុស្ស ឡើងបញ្ចេញមតិរបស់ខ្លួននៅក្នុងសភា ដោយសារសមាជិកសភាទាំងននេះចង់រក្សាឯករាជ្យភាពរបស់ខ្លួនពីគណៈបក្សនយោបាយដទៃនិងមិនបានចូលរួមក្នុងក្រុមណាមួយ។

29. ជាថ្មីម្តងទៀត ករណីរបស់លោក សម រង្ស៊ី និងលោក ជាម ចាន្នី បង្ហាញឲ្យឃើញពីអ្វីដែលផ្ទុយទៅនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និង មាត្រាទី១៩ របស់ ICCPR និងមាត្រាទី ៣១ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ ដូចបានបង្ហាញខាងលើ ការប្រើច្បាប់បរិហាកេរ្តិ៍ក្នុងច្បាប់ព្រហ្មទណ្ឌខ្លួនឯងរំលោភលើកាតព្វកិច្ចអន្តរជាតិ និងរដ្ឋធម្មនុញ្ញរួចស្រេចទៅហើយ។ មាត្រា៧៧នៃរដ្ឋធម្មនុញ្ញចែងថា "តំណាងរាស្ត្រនៃរដ្ឋសភាជាតំណាងប្រជាជាតិទាំងមូល ពុំគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ អណត្តិអជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ។" ចំពោះបទបញ្ជាផ្ទៃក្នុងថ្មីប្រើក្នុងសភាហាមសមាជិកសភាមិនឲ្យប្រើសិទ្ធិសេរីភាពបញ្ចេញមតិ និងរារាំងអ្នកទាំងនោះមិនឲ្យតំណាងប្រជាពលរដ្ឋខ្មែរ។

### *៣) ការត្រួតពិនិត្យលើប្រព័ន្ធផ្សព្វផ្សាយ*

30. អ្នកកាសែត និពន្ធនាយក និងអ្នកពត៌មានផ្សេងទៀតត្រូវទទួលរង របួសស្នាម ការគំរាមគំហែង ការប្តឹងពីបទបរិហារកេរ្តិ៍ និង/រឺបទផ្សាយពត៌មានមិនពិត។ ការរាយការណ៍លើប្រធានបទរសើបគឺជារឿងប្រថុយប្រថាន។

- នៅខែវិច្ឆិកា ឆ្នាំ២០០៧ ក្រសួងមហាផ្ទៃ និងក្រសួងពត៌មានបានដកហូតយកទស្សនាវដ្តីសារពត៌មានសេរីពីតូបលក់កាសែត។ ទស្សនាវដ្តីនេះបានបោះផ្សាយអត្ថបទ និងរូបថ្លុករិះគន់ដល់អតីតព្រះមហាក្សត្រ ព្រះបាទនរោត្តមសីហនុ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ អ្នកបោះពុម្ពផ្សាយត្រូវបញ្ជាឲ្យបិទការផ្សាយរបស់ខ្លួន ហើយនិពន្ធនាយក ឡឹម ពិសិដ្ឋ ត្រូវកោះហៅចូលក្នុងក្រសួងមហាផ្ទៃ។ ក្រោយមកលោក ឡឹម ពិសិដ្ឋ បានទទួលសារគំរាមក្នុងទូរសព្ទដៃពីខែមករាដល់ខែមេសាឆ្នាំ២០០៨ នឹងគ្រាប់កាំភ្លើង AK47 ត្រូវបានដាក់បង្កៀនៅក្បែរផ្ទះ។ គាត់បានរត់គេចខ្លួនទៅបរទេសនៅខែឧសភាឆ្នាំ ២០០៨។
- នៅខែឧសភាឆ្នាំ ២០០៨ ក្រសួងពត៌មានបានបិទស្ថានីយវិទ្យុអង្គររដ្ឋានៅខេត្តក្រចេះ និងដកហូតអជ្ញាប័ណ្ណ បន្ទាប់ពីវិទ្យុនេះបានលក់ម៉ោងផ្សាយទៅឲ្យគណៈបក្សនយោបាយ៤ ដោយគ្មានការអនុញ្ញាត។ សកម្មភាពនេះសរបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកំរិតប្រោកង់វិទ្យុមិនឲ្យផ្សាយបានទូលំទូលាយចំពោះស្ថានីយវិទ្យុ ដែលមានសមានចិត្តចង់ផ្សាយឲ្យគណៈបក្សប្រឆាំងនិងអង្គការសិទ្ធិមនុស្សនានា។
- នៅខែមិថុនា ឆ្នាំ២០០៨ លោក ដាំ សិទ្ធិ ជានិពន្ធនាយកកាសែត"មនសិការខ្មែរ"ត្រូវបានចាប់ខ្លួនពីបទផ្សាយពត៌មានមិនពិត ក្នុងការរាយការណ៍ពីសន្ទរកថារបស់មេដឹកនាំគណៈ

បក្សប្រឆាំង ដែលថាមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលពីរនាក់មានជាប់ពាក់ពន្ធ័នឹងរបបខ្មែរក្រហម។ ករណីនេះត្រូវបិទភ្លាមនៅពេល លោក ដាំ សិទ្ធិបានសុំទោសពីកំហុសរបស់ខ្លួន។

- រឿងដែលកាន់តែសំខាន់នោះគឺ នៅដើមខែកក្កដា ឆ្នាំ២០០៨ អ្នកកាសែត ឃឹម សម្បូរណ៍ របស់កាសែតមនសិការខ្មែរត្រូវបានបាញ់សម្លាប់ ជាមួយនឹងកូនប្រុសនៅទៅក្រុងភ្នំពេញ។ គ្មានការចាប់ខ្លួនជនសង្ស័យណាមួយទេ។
- នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៩ ការដេញប្រជាពលរដ្ឋដោយអំពើហឹង្សានៅសហាគមដីក្រហមក្រុងភ្នំពេញ ក៏បង្ហាញឲ្យឃើញពីការប្រើកំលាំងច្បាប់របស់មន្ត្រីដើម្បីរារាំងអ្នកកាសែតក្នុងការយកពត៌មានលើករណីនេះដែរ។
- នៅឆ្នាំ២០០៩ យើងឃើញមានឈានទៅដល់ការកំរិតសេរីភាពបញ្ចេញមតិនៅលើអិនធឺណែត។ តាមការរាយការណ៍ឲ្យដឹងថា រដ្ឋាភិបាលបានបិទវែបសាយពីរគឺឃ្លាំមើលសកលលោក (Global Witness) និងវែបសាយរាហ៊ូ(reahu.net)។

31. ជាថ្មីម្តងទៀត យើងគួរបញ្ជាក់អំពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង មាត្រាទី១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា៣១ និង៤១ នៃរដ្ឋធម្មនុញ្ញ។ សេរីភាពបញ្ចេញមតិរបស់អ្នកសារពត៌មាន និងបុគ្គលិកខាងពត៌មានដទៃទៀតត្រូវបានគេរឹតត្បិតយ៉ាងខ្លាំងនៅក្នុងដំណាក់កាលនេះ។ ការរំលោភទាំងនេះធ្វើឡើងដោយផ្ទុយទៅនឹងច្បាប់ស្តីពីរបបសារពត៌មានឆ្នាំ១៩៩៥ ដែលការពារឲ្យមានសេរីភាពបញ្ចេញមតិ។ មាត្រាទី១បញ្ជាក់ថា *"ច្បាប់នេះកំណត់របបសារពត៌មាននិងធានារ៉ាប់រងសេរីភាពខាងការបោះពុម្ពផ្សាយឲ្យបានសមស្របតាមមាត្រាទី៣១ និង៤១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។"* ប៉ុន្តែទោះយ៉ាងនេះក៏ដោយ ច្បាប់ស្តីពីរបបសារពត៌មាននេះនៅមានចំនុចចន្លោះប្រហោងយ៉ាងច្រើនដោយសារមានមាត្រាមួយចំនួនត្រូវបានគេធ្វើឡើងឬត្រូវបានគេបកស្រាយដើម្បីធ្វើការដាក់កំរិតឬគាបសង្កត់លើរបបសារពត៌មាន។ យើងភ្ជាប់មកជាមួយនឹងការវិភាគយ៉ាងលំអិតពីច្បាប់សារពត៌មាន យោងតាមមាត្រាទី១៩នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ [12] ទោះបីជាការអង្កេតនិងការរិះគន់ទាំងនៅក្នុងសេចក្តីរាយការណ៍គួរអោយព្រួយបារម្ភនាពេលថ្មីៗ ក្រសួងពត៌មានអះអាងថាខ្លួនមានផែនការពង្រឹងការគ្រប់គ្រងរបស់ខ្លួនទៅលើការបោះពុម្ពផ្សាយនិងការចែកផ្សាយ ព្រមទាំងពង្រីកច្បាប់សារពត៌មានគ្រប់គ្រងលើប្រព័ន្ធអិនធឺណែតផងដែរ[13]។

## *៤) ការរារាំងសេរីភាពទទួលពត៌មាន*

32. សិទ្ធិទទួលពត៌មាន ដែលជាផ្នែកមួយដ៏សំខាន់នៃសេរីភាពបញ្ចេញមតិ ត្រូវបានរឹតត្បិតយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ ដំណើរការធ្វើសេចក្តីសំរេចរបស់រដ្ឋាភិបាលធ្វើឡើងក្នុងភាពសំងាត់ ហើយចំពោះការប៉ះពាល់ផលប្រយោជន៍របស់បុគ្គលឯកជន តែងនាំទៅរកការគំរាមកំហែងដល់អ្នកសារពត៌មានផ្នែកស៊ើបអង្កេត។

- នៅថ្ងៃទី២៥ខែធ្នូឆ្នាំ២០០៧ មន្ត្រីយោធាម្នាក់បានដកហូតពត៌មានពីលោក ស៊ូ វិសាល នៅវត្តនិរោធន៍ក្នុងក្រុងភ្នំពេញ ដែលជាអ្នកយកការណ៍ឲ្យវិទ្យុសំលេងប្រជាធិបតេយ្យ។ លោក

[12] មាត្រាទី១៩ Op. cit.

[13] ‘Ministry To Tighten Broadcast Control,’វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA), ពេជ្រ សំណាង, ភ្នំពេញ, ២០ មិនា ២០០៩។

ស៊ូ វិសាល កំពុងធ្វើការស៊ើបអង្កេតលើពត៌មានដែលលោកទទួលបានថាមានអ្នករងរបួស និងអ្នកស្លាប់ដោយសារវាយកំទេចចោលពុទ្ធបដិមាករនៅទីនោះ។ មន្ត្រីយោធាធ្វើការគំរាមលោក ស៊ូ វិសាលនិងដកហូតយកប្រដាប់ថតសម្លេង និងម៉ាស៊ីនថតពីលោក។ បន្ទាប់ពីលុបរូបថតនិងសំលេងអស់ ទើបមន្ត្រីយោធានោះប្រគល់សំភារៈនោះមកវិញ។

- នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ អ្នកយកពត៌មានពីររូបមកពីកាសែតខ្មែរម្ចាស់ស្រុកនិងកាសែតស្រលាញ់ខ្មែរ ត្រូវបានហាមឃាត់មិនឲ្យយកពត៌មានស្តីអំពីជំលោះដីធ្លីមួយកន្លែងរវាងប្រជាពលរដ្ឋបីគ្រួសារនិងក្រុមហ៊ុនផានអ៊ីមិច នៅភូមអណ្តូង សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ។ ក្រុមហ៊ុននេះបានជួលជនប្រដាប់អាវុធមកយាមដី ហើយជនប្រដាប់អាវុធនេះបានយកកាំភ្លើងមកគំរាមអ្នកកាសែតទាំងពីររូប ដោយប្រមានមិនឲ្យថតរូប។
- នៅខែកក្កដា ឆ្នាំ២០០៨ រដ្ឋាភិបាលបានពន្យាការចេញផ្សាយតួលេខអតិផរណា ដែលទំនងជាដើម្បីជៀសវាងផលប៉ៈពាល់អវិជ្ជមានជាសាធារណៈ ក្នុងកំលុងពេលបោះឆ្នោតថ្នាក់ជាតិ។
- ខណៈពេលដែលតុលាការជាតិបរាជ័យក្នុងស៊ើបអង្កេតឲ្យ បានត្រឹមត្រូវពិបទចោទប្រកាន់អំពើពុករលួយនៅតុលាការខ្មែរក្រហម អង្គការសហប្រជាជាតិបរាជ័យក្នុងការចែករំលែកលទ្ធផលនៃការស៊ើបអង្កេតនៅក្នុងបទចោទប្រកាន់នេះ។ អង្គការសហប្រជាជាតិគឺកំពុងបិទសិទ្ធិទទួលពត៌មានដែលអាចប៉ះពាល់ដល់ការកាត់ក្តីដោយយុត្តិធម៌។ ការធ្វើដូច្នេះគឺជាសញ្ញាថាអំពើពុករលួយអាចអត់អោនឲ្យបាន ដោយឲ្យអទិភាពនិទន្នភាពជាងការទទួលខុសត្រូវ។

33. រដ្ឋាភិបាលនិងក្រុមដែលមានទំនាក់ទំនងស្និតនឹងខ្លួន បានធ្វើការរឹតត្បិតសេរីភាពទទួលពត៌មានដោយរំលោភលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រាទី១៩នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រាទី៣១ និង៤១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ យើងសង្ឃឹមថា ក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលពត៌មានដែលធ្វើឡើងដោយមានជំនួយបច្ចេកទេសពីសហរដ្ឋអាមេរិក នឹងធ្វើឲ្យការរឹតត្បិតនេះមានការថមថយដែរ។

### *៥) ការរារាំងការជួបប្រជុំនិងបាតុកម្មនៅទីសាធារណៈ*

34. យោងលើរបាយការណ៍របស់អង្គការអាដហុកក្នុងឆ្នាំ២០០៨ យ៉ាងហោចណាស់បាតុកម្មអហឹង្សាចំនួន១០៨ក្នុងចំណោមបាតុកម្ម១៥៥ដែលភាគច្រើនពាក់ព័ន្ធនឹងរឿងដីធ្លីនិងកម្មករ ត្រូវបានអាជ្ញាធរបង្ក្រាប។ [14] រដ្ឋាភិបាលកម្ពុជាធ្វើការរឹតបណ្តឹងយ៉ាងខ្លាំងលើការជួបប្រជុំនិងការធ្វើបាតុកម្មនៅតាមទីសាធារណៈ និងតែងតែប្រើប្រាស់នូវអំពើហឹង្សាខុសច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់។

- ព្រឹត្តិការណ៍ជុំវិញការបាញ់សំលាប់ប្រធានសហជីពសេរីកម្មករកម្ពុជា លោកជា វិជ្ជា បង្ហាញនូវរូបភាពធំរួមមួយស្តីអំពីការរឹតត្បិតសេរីភាពបញ្ចេញមតិនិងការជួបប្រជុំនៅកម្ពុជា។ មានការចោទប្រកាន់ថាលោក ជា វិជ្ជា ត្រូវបានគេសំលាប់ដោយសារការបញ្ចេញមតិរបស់លោកប្រឆាំងនឹងរដ្ឋាភិបាល។ ប្រធានគណៈបក្សប្រឆាំងលោកសមរង្ស៊ីត្រូវបានគេកាត់ទោសដោយសារការបញ្ចេញមតិរបស់លោក។ នៅខែកញ្ញា ឆ្នាំ២០០៦ ការតវ៉ាដោយសន្តិវិធីនៅក្រៅមន្ទីរឃុំឃាំងប្រឆាំងនឹងការកាត់ទោសចំពោះអ្នកដែលគេចោទថា ជាឃាតករត្រូវ

[14] ស្ថានភាពសិទ្ធិមនុស្សនៅឆ្នាំ២០០៨ សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(Adhoc) ខែមករា២០០៩។

បានប៉ូលីសប្រើអំពើហិង្សាបំបែក។ លោក ហេង ពៅ ជាអតីតមន្ត្រីប៉ូលីសទទួលបន្ទុកស៊ើបអង្កេតលើឃាតកម្មនេះ ហើយលោកឥឡូវបានចោទប្រកាន់អគ្គមេបញ្ជាការប៉ូលីសលោក ហុក ឡុងឌី ជាអ្នកបញ្ជាពីក្រោយខ្នង។ សព្វថ្ងៃលោកហេងពៅត្រូវកាត់ទោសឲ្យជាប់គុក៧៦ឆ្នាំដោយសារបទល្មើសព្រហ្មទណ្ឌជាច្រើន។ លោក ហុក ឡុងឌី បានស្លាប់នាពេលថ្មីៗនេះដោយសារធ្លាក់យន្តហោះ។

- កូដកម្មដោយកម្មការនីនៅក្រុមហ៊ុនហ្វជូនហ្វាមិនវូលិនណាយធីង នៅខេត្តកាលពីថ្ងៃទី២៩ ខែវិច្ឆិកាឆ្នាំ២០០៧ត្រូវបានបំបែកយ៉ាងឃោឃៅ ដោយក្រុមប៉ូលីសមួយក្រុមធំប្រដាប់ដោយដំបងឆក់ និងកាំភ្លើងបង្ហូរទឹកភ្នែកដែលធ្វើឲ្យកម្មការនីមួយចំនួនរងរបួស។
- នៅខែធ្នូ ឆ្នាំ២០០៧ បាតុកម្មអហិង្សារបស់ព្រះសង្ឃកម្ពុជាក្រោមចំនួន៥៨អង្គនៅមុនស្ថានទូតវៀតណាមត្រូវបានបំបែកដោយកំលាំងប៉ូលីសដ៏ច្រើនលើសលប់ ហើយការបំបែកនេះបានធ្វើឲ្យព្រះសង្ឃពីរអង្គរងរបួសយ៉ាងធ្ងន់ធ្ងរ។
- នៅថ្ងៃទី១៩ ខែធ្នូ ២០០៧ ប៉ូលីស និងទាហានប្រដាប់ដោយដំបងឆក់ និង មានឡានទឹកបានបាញ់ទឹកបំបែកក្បួនដង្ហែដោយសន្តិវិធីរបស់ក្រុមជនជាតិភាគតិច១៦០នាក់ នៅឃុំឡាបានសៀក ស្រុកបាឡុង ខេត្តរតនគីរី។ អជ្ញាធរមូលដ្ឋានមិនបានអនុញ្ញាតចំពោះការដង្ហែរក្បួននេះទេ។ ប៉ូលីសបានកោះហៅអ្នករៀបចំក្បួនដង្ហែរនិងសកម្មជនសិទ្ធិមនុស្សម្នាក់មកសាកសួរ និងចូលឆែកឆេរខុសច្បាប់នៅផ្ទះសកម្មជនសិទ្ធិមនុស្សម្នាក់ទៀត។
- ចាប់ពីខែមករាដល់ខែតុលាឆ្នាំ២០០៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរៀបចំវេទិកាសាធារណៈចំនួន៥៨ ដោយក្នុងនោះវេទិកាចំនួន៩ត្រូវបានរំខាននិងវេទិកាចំនួន២ត្រូវបានរាំង។ អាជ្ញាធរមូលដ្ឋានបានរាំងវេទិកាចំនួន២ (ដែលត្រូវរៀបចំនៅខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង) ដោយសារពួកគេចង់រក្សាឲ្យមានសណ្តាប់ធ្នាប់ល្អក្នុងកំឡុងពេលនៃការបោះឆ្នោតថ្នាក់ជាតិ។

35. ករណីខាងលើទាំងអស់នេះ គ្រាន់តែជាឧទាហរណ៍មួយចំនួនក្នុងចំណោមករណីជាច្រើនដែលរដ្ឋាភិបាលបានធ្វើការរិតត្បិតសេរីភាពបញ្ចេញមតិ និងការជួបប្រជុំដែលផ្ទុយទៅនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមាត្រា២០ និង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមាត្រា២១ និងមាត្រាទី៣១ មាត្រា៣៧និងមាត្រា៤១នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

36. ក្នុងការគៀបសង្កត់លើសេរីភាពជួបប្រជុំ រដ្ឋាភិបាលជារឿយៗតែងសំអាងលើច្បាប់ស្តីពីបាតុកម្មឆ្នាំ១៩៩១ ដែលហាមឃាត់រាល់ការដង្ហែរក្បួនឬបាតុកម្មទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់*"សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ"*។ ជាងនេះទៅទៀត អាជ្ញាធរមូលដ្ឋានបកស្រាយខុសទៅលើច្បាប់ ហើយផ្អែកលើសេចក្តីប្រកាសក្រសួងមហាផ្ទៃដែលតំរូវឲ្យអ្នករៀបចំបាតុកម្មទទួលការអនុញ្ញាតដើម្បីធ្វើបាតុកម្ម។ ច្បាប់បាតុកម្មឆ្នាំ១៩៩១ មិនត្រូវក្រុមប្រឹក្សាធម្មនុញ្ញយល់ស្របនោះទេ។ ប៉ុន្តែច្បាប់ថ្មីដែលកំពុងស្ថិតក្នុងសេចក្តីព្រាងមានចំនុចជាច្រើនមិនប្រសើរជាងច្បាប់បាតុកម្ម១៩៩១ ពីព្រោះវាមានចំនុចខ្វែងគ្នាជាច្រើន និងតំរូវឲ្យអ្នករៀបចំបាតុកម្មសុំការអនុញ្ញាតដើម្បីធ្វើបាតុកម្មទៀតផង។ មិនតែប៉ុណ្ណោះ ច្បាប់ថ្មីនេះទាមទាឲ្យអ្នករៀបចំបាតុកម្មទទួលខុសត្រូវរាល់ការខូចខាតដែលបង្កឡើងដោយអ្នកចូលរួមធ្វើបាតុកម្មទៀតផង។

## V. សមិទ្ធិផល ការអនុវត្តន៍ល្អៗ ការប្រឈម និងឧបសគ្គ

37. យើងទទួលស្គាល់អំពីការបង្ហាញពីចេតនារបស់រដ្ឋាភិបាល ក្នុងការបន្តធ្វើការជាមួយសមាគមអាស៊ានក្នុងការបង្កើតឲ្យមានស្ថាប័នសិទ្ធិមនុស្សសំរាប់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ការបង្កើតឲ្យមានស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ និងលុបចោលបទបរិហាកេរ្តិ៍ចេញពីទោសព្រហ្មទណ្ឌ

ទាំងស្រុង។ ហើយយើងក៏សង្ឃឹមដែរថា រដ្ឋាភិបាលនឹងបង្កើតច្បាប់ស្តីពីការទទួលពត៌មាន។ យើងជឿជាក់ថារាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនឹងធ្វើការជាមួយគ្នាអោយកាន់តែប្រសើរជាងមុន។

38. ទោះបីជាយ៉ាងនេះក៏ដោយ យើងមានការព្រួយបារម្ភអំពីបរាជ័យរបស់រដ្ឋាភិបាលក្នុងការសហការជាមួយសហគមអន្តរជាតិ និងអំពីចំនុចខ្សោយរបស់សហគមអន្តរជាតិក្នុងការទាមទារឲ្យមានការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ លើសពីនេះទៀត កម្ពុជាពុំមានយន្តការឯករាជ្យណាមួយដែលដើរតួនាទីជាអ្នកត្រួតពិនិត្យលើអំណាចរបស់រដ្ឋាភិបាល។ ដូច្នេះ ការរំលោភលើសេរីភាពបញ្ចេញមតិ និងការជួបប្រជុំនៅតែកើតមានឡើង។ យើងក៏មានការព្រួយបារម្ភផងដែរពីវិធីសាស្ត្ររបស់រដ្ឋាភិបាលពាក់ពន្ធ័នឹងប្រពន្ធ័អ៊ីនធឺណែត និងផែនការរឹតបន្តឹងលើការប្រើប្រាស់ប្រពន្ធ័នេះ។

## VI <u>**អធិភាព ការផ្តួចផ្តើម និងការប្តេជ្ញាចិត្តចំបងៗរបស់រដ្ឋាភិបាល**</u>

39. ក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយនេះ ប្រជាពលរដ្ឋខ្មែរតែងបានទទួលរងនូវការរំលោភជាញឹកញាប់លើសិទ្ធិសេរីភាពបញ្ចេញមតិនិងការជួបប្រជុំ។ ដើម្បីធ្វើឲ្យស្ថានភាពនេះមានការប្រសើរឡើង យើងទទូចឲ្យរដ្ឋាភិបាលកម្ពុជាគោរពយ៉ាងខ្ជាប់ខ្ជួននូវសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ និងអនុវត្តឲ្យបានជិតដល់នូវអនុសាសន៍ខាងក្រោមនេះ៖

***ថ្នាក់អន្តរជាតិ***

I. ឲ្យសច្ចាប័នលើពិធីសារតាមចិត្តជ្រើសរើសទី១ជាប់នឹងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីអនុញ្ញាតិឲ្យពលរដ្ឋកម្ពុជាគ្រប់រូបអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពក្នុងការជួបប្រជុំ និងសិទ្ធិផ្សេងទៀតជូនទៅគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។
II. ធ្វើការជាមួយនឹងសង្គមស៊ីវិល ដើម្បីសហការជាមួយស្ថាប័នត្រួតពិនិត្យអនុសញ្ញា/កតិកាសញ្ញាដែលកម្ពុជាបានឲ្យសច្ចាប័ន ជាពិសេសជាមួយគណៈកម្មការសិទ្ធិមនុស្ស។
III. អញ្ជើញតំណាងពិសេសរបស់អង្គការសហប្រជាជាតិខាងការលើកស្ទួយ និងការពារសេរីភាពបញ្ចេញមតិមកធ្វើទស្សនកិច្ច និងធ្វើការវាយតំលៃអំពីស្ថានភាពនៅកម្ពុជា និងផ្តល់អនុសាសន៍ដើម្បីពង្រឹងសេរីភាពបញ្ចេញមតិឲ្យកាន់តែប្រសើរឡើង។
IV. ធ្វើសហប្រតិបត្តិការឲ្យបានពេញលេញជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា។
V. ធ្វើសហប្រតិបត្តិការឲ្យបានល្អនៅក្នុងដំណើរការត្រួតពិនិត្យជាសកលតាមពេលកំណត់នេះ ដោយធ្វើការពិភាក្សាជាមួយភាគីពាក់ព័ន្ធទាំងអស់។

***ថ្នាក់តំបន់***

VI. ធ្វើការជាមួយសមាជិកអាស៊ានដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សអាស៊ាននៅឆ្នាំ២០០៩។

**ថ្នាក់ជាតិ**

VII. បង្កើតឲ្យបាននូវគណៈកម្មការសិទ្ធិមនុស្សជាតិមួយដែលឯករាជ្យ ឲ្យស្របតាមគោលការណ៍នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

VIII. ធ្វើការទទួលយកជាសាធារណៈនូវគោលការណ៍ទីក្រុងជរហោណាសបឺក និងធ្វើការជាមួយអង្គការសង្គមស៊ីវិល ដើម្បីបង្កើតជាយុទ្ធសាស្ត្រនិងផ្សព្វផ្សាយអំពីសេរីភាពបញ្ចេញមតិនិងជួបប្រជុំជាផ្នែកមួយនៃផែនការការពារសិទ្ធិមនុស្សរបស់ជាតិ។

IX. ដកបទបរិហារកេរ្តិ៍និងផ្សាយពត៌មានមិនពិតចេញពីបទល្មើសបទព្រហ្មទណ្ឌ។

X. ធ្វើការអញ្ជើញអ្នកជំនាញការរាប់បញ្ចូលទាំងអង្គការអន្តរជាតិមាត្រាទី១៩ និងអង្គការសហប្រជាជាតិខាងការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌(យូណេស្កូ) ដើម្បីធ្វើការវាយតំលៃ និងផ្តល់ជាអនុសាសន៍លើច្បាប់ស្តីពីរបបសារពត៌មានឆ្នាំ១៩៩៥ និងច្បាប់ស្តីការធ្វើបាតុកម្ម១៩៩១។ អនុវត្តន៍នូវច្បាប់ដែលធ្វើវិសោធនកម្មទាំងនេះ។

XI. បង្កើតច្បាប់សេរីភាពទទួលពត៌មាន ដោយផ្អែកលើសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលពត៌មាន។

XII. ធានាឲ្យបានថា ច្បាប់ស្តីអំពីអង្គការសមាគមន៍ក្រៅរដ្ឋាភិបាលអនុលោមតាមសេរីភាពបញ្ចេញមតិ និងសមាគម។

XIII. ធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាដោយដកការបង្ខំឲ្យចងជាក្រុម ដើម្បីជំរុញឲ្យសមាជិកសភានិយាយដោយសេរីនិងអាចតំណាងឲ្យម្ចាស់ឆ្នោតរបស់ខ្លួនបាន។

XIV. ផ្តល់ប្រេកង់វិទ្យុឲ្យបានកាន់តែច្រើន ដើម្បីឲ្យស្ថានីយដែលមានបំណងជួយផ្សព្វផ្សាយគណៈបក្សនយោបាយប្រឆាំង និងអង្គការសង្គមស៊ីវិលបានប្រើប្រាស។

XV. ផ្តល់នូវការបណ្តុះបណ្តាលដល់មន្ត្រីតុលាការ មន្ត្រីយុត្តិធម៌ និងមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋានអំពីសារសំខាន់នៃការប្រើប្រាស់គោលការណ៍អន្តរជាតិស្តីពីសេរីភាពបញ្ចេញមតិ និងការជួបប្រជុំក្នុងការបកស្រាយច្បាប់និងអាកប្បកិរិយារបស់ខ្លួន។

XVI. ធ្វើកំណែទម្រង់លើប្រពន្ធ័តុលាកាដើម្បីឲ្យមានឯករាជ្យពិតប្រាកដ។ ការផ្តល់អនុសាសន៍ជាក់ស្តែងសំរាប់ធ្វើកំណែទម្រង់តុលាការគឺហួសពីដែនកំណត់នៃរបាយការណ៍រូមនេះ ដូច្នេះយើងយោងចំណុចនេះទៅរបាយការណ៍ដែលធ្វើឡើងដោយអង្គការលីកាដូ។ [15]

## VII ការពង្រឹងសមត្ថភាព និងជំនួយបច្ចេកទេស

40. អនុសាសន៍ខាងលើបង្ហាញថា ការពង្រឹងសមត្ថភាពនិងជំនួយបច្ចេកទេសមានសារសំខាន់។ គេចាំបាច់ត្រូវធ្វើការពង្រឹង និងជំរុញឲ្យរដ្ឋាភិបាលសហការបន្ថែមទៀតជាមួយរាល់យន្តការរបស់អង្គការសហប្រជាជាតិ បង្កើតឲ្យបានស្ថាប័នសិទ្ធិមនុស្សជាតិមួយដែលឯករាជ្យ ធ្វើការកែទំរង់រាល់ច្បាប់ទាំងឡាយដែលមានចន្លោះប្រហោង និងផ្តល់ការបណ្តុះបណ្តាល។ អង្គការសង្គមស៊ីវិលក៏អាចទទួលបាននូវផលប្រយោជន៍ពីការពង្រឹងសមត្ថភាពនិងជំនួយបច្ចេកទេស ដើម្បីឲ្យការងាររបស់ខ្លួនកាន់តែមានប្រសិទ្ធិភាពក្នុងការលើកស្ទួយ និងការពារសេរីភាពបញ្ចេញមតិនិងការជួបប្រជុំ និងសិទ្ធិដទៃទៀតផងដែរ។

១៣ មេសា ២០០៩

[15] របាយការណ៍ លីកាដូ

ឧបសម្ព័ន្ធ១ ៖ អាសយដ្ឋានរបស់សម្ព័ន្ធអង្គការ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API)
មជ្ឈមណ្ឌលភ្នំពេញ អគា F ជាន់ទី៤ បន្ទប់លេខ ៤៨៤ កែងផ្លូវសីហានុ និងមហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៣ ៨៨៦
ទូរសារ ៖ (៨៥៥) ២៣ ២១៣ ៨៨៧
អ៊ីម៉ែល ៖ apioffice@apiinstitute.org
វែបសាយ ៖ www.apiinstitute.org

មជ្ឈមណ្ឌលផ្នែកច្បាប់អាស៊ី(ALRC)
19/F, Go-Up Commercial Building, 998 Canton Road, Kowloon,ទីក្រុងហុងកុង ប្រទេសចិន
ទូរស័ព្ទ ៖ (៨៥២) ២៦៩៨ ៦៣៣៩
ទូរសារ ៖ (៨៥២) ២៦៩៨ ៦៣៦៧
អ៊ីម៉ែល ៖ alrc@alrc.net
វែបសាយ ៖ www.alrc.net

សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC)
ផ្ទះលេខ ១ ផ្លូវ ១៥៨ ឧកញ្ញាទ្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៨ ៦៥៣
អ៊ីម៉ែល ៖ adhoc@forum.org.kh
វែបសាយ ៖ www.adhoc-chra.org

សមាគមកម្ពុជាដើម្បីការពារអ្នកសារពត៌មាន(CAPJ)
ផ្ទះលេខ ៦៣ ផ្លូវ ២៤០ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
ប្រអប់សំបុត្រលេខ ៨១៦ ភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥) ១២ ៩៩៧ ០៥៤
ទូរសារ ៖ (៨៥៥) ២៣ ២១៥ ៨៣៤
អ៊ីម៉ែល ៖ umsarin@gmail.com

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
ផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៧២៦ ៩០១
ទូរសារ ៖ (៨៥៥) ២៣ ៧២៦ ៩០២
អ៊ីម៉ែល ៖ info@cchrcambodia.org
វែបសាយ ៖ www.cchrcambodia.org

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
ផ្ទះលេខ ១៩អា ផ្លូវ ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៧២៦ ៨៤២
ទូរសារ ៖ (៨៥៥) ២៣ ៧២៦ ៨៤៣
អ៊ីម៉ែល ៖ info@vodradio.org
វែបសាយ ៖ www.vodradio.org

មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
ផ្ទះលេខ ២២ ផ្លូវ ២២ ក្រុមលេខ ៣ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥)២៣ ៨៨០ ៦៩០
អ៊ីម៉ែល ៖ ccpcr@online.org.kh

សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA)
ផ្ទះលេខ ៥៤អឺស្សេ ផ្លូវ ៩៥ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ១២ ៩៣០ ៧០៦

សមាគមមន្ត្រីរាជការឯករាជ្យ (CICA)
ផ្ទះលេខ ៥ ផ្លូវ ៨៧០ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ១៧ ២៦៦ ៨៥០
អ៊ីម៉ែល ៖ thimsea@yahoo.com

សម្ព័ន្ធជំរឿនការពារសិទ្ធិមនុស្សលីកាដូ (LICADHO)
ផ្ទះលេខ ១៦ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៣៦៤ ៩០១
ទូរសារ ៖ (៨៥៥) ២៣ ២១៧ ៦២៦
អ៊ីម៉ែល ៖ contact@licadho.org
វែបសាយ ៖ www.licadho-cambodia.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)
ផ្ទះលេខ ១៩ ផ្លូវ ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៣៦៤ ៧៣៦
ទូរសារ ៖ (៨៥៥) ២៣ ៣៦៤ ៧៣៦
អ៊ីម៉ែល ៖ contact@licadho.org
វែបសាយ ៖ www.licadho-cambodia.org

មជ្ឈមណ្ឌលដើម្បីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (CCPR)

ផ្លូវ Rue de Vermont 37-39, ប្រអប់សំបុត្រលេខ ១៨៣, ១២១១ ទីក្រុងហ្សឺណែវ ២០ ប្រទេសស្វីស
ទូរស័ព្ទ ៖ ៨១ (០)២២/ ៥៩៨ ៣៨០៣
អ៊ីម៉ែល ៖ info@ccprcentre.org

សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C-CAWDU)
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា Tel: (855) 12 998 906
អ៊ីម៉ែល៖ c.cawdu@forum.org.kh
វែបសាយ៖ http://ccawdu.typepad.com

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (COMFREL)
ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់២ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨៤ ១៥០
ទូរសារ ៖ (៨៥៥) ២៣ ៨៨៣ ៧៥០
អ៊ីម៉ែល ៖ comfrel@online.com.kh
វែបសាយ ៖ www.comfrel.org

មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC)
ផ្ទះលេខ៥៨ ផ្លូវ ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៥ ៥៩០
ទូរសារ ៖ (៨៥៥) ២៣ ២១១ ៧២៣
អ៊ីម៉ែល ៖ admin@clec.org.kh
វែបសាយ ៖ www.clec.org.kh

សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
ផ្ទះលេខ១១ ផ្លូវ ៣៧៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៦ ៨៧០
ទូរសារ ៖ (៨៥៥) ២៣ ២១៦ ៨៧០
អ៊ីម៉ែល ៖ contact@ftuwkc.org
វែបសាយ ៖ www.ftuwkc.org

សមាគមប្រជាធិបតេយ្យឯករាជ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
ផ្ទះលេខ៦សេ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ១២ ៥៤៣ ៧៩៦

សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH)
៧ សេ ផ្លូវ passage de la Main d’Or បារីស ប្រទេសបារាំង
ទូរស័ព្ទ ៖ + ៣៣ (0) ១ ៤៣៥៥២៥ ១៨-
ទូរសារ ៖ + ៣៣ (0) ១ ៤៣៥៥១៨៨០
អ៊ីមែល ៖ fidh@fidh.org

សមាគមខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRA)
ផ្ទះលេខ១៨៣ ផ្លូវ ១៦៣ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩៣ ៨៨៦ រឺ (៨៥៥) ១២ ២៥៩ ៩៩២
អ៊ីម៉ែល ៖ chanrithang@yahoo.com

សមាគមយុវជនខ្មែរ (KYA)
ផ្ទះលេខ១៣៥អា ផ្លូវ ២៥៩ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨៤ ៣០៦
ទូរសារ (៨៥៥) ២៣ ៨៨៤៣០៦
អ៊ីម៉ែល ៖ admin@kya-cambodia.org
វែបសាយ ៖ www.kya-cambodia.org

ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
ផ្ទះលេខ៥៥បេសេ ផ្លូវ ៣៩០ សង្កាត់បឹងកេងកង៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៣ ៣៧៦
ទូរសារ (៨៥៥) ២៣ ២១៣ ៣៧៩
អ៊ីម៉ែល ៖ lac@lac.org.kh
វែបសាយ ៖ www.lac.org.kh

គណៈកម្មាធិការអព្យាក្រិតនិងមិនលំអៀងសំរាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា(NECFEC)
ផ្ទះលេខ១៦បេ ផ្លូវ ៣៨៨ សង្កាត់បឹងកេងកង៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រលេខ ១២៣៣ ស៊ីស៊ីស៊ី ប្រអប់សំបុត្រ ២១០
ទូរស័ព្ទ ៖ (៨៥៥) ២៣៩៩៣ ០៣៧
ទូរសារ (៨៥៥) ២៣ ៩៩៣ ៦៦៦
អ៊ីម៉ែល ៖ nicfec@wicam.com.kh
វែបសាយ ៖ www.nicfec.org

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍(PDP-Center)
ផ្ទះលេខ១៣៣បេ ផ្លូវ ២៥៩ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨៣ ៣០៤
ទូរសារ (៨៥៥) ២៣ ៨៨៣ ៣០៤
អ៊ីម៉ែល ៖ pdpcenter@yahoo.com or kimeng_yong@yahoo.com

អង្គការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ(PADV)
ផ្ទះលេខ៩៧-៩៩ ផ្លូវ ២១០ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨១ ៩៥៦
ទូរសារ (៨៥៥) ២៣ ៩៩៨ ២៩៣
អ៊ីម៉ែល ៖ padv@online.com.kh

សម្ព័ន្ធសារពត៌មានអាស៊ីអគ្នេយ៍ (SEAPA)

EAPA Headquarters
Sam-Sen Rd. Dusit Bangkok Thailand 10300
ទូរស័ព្ទ/ទូរសារ ៖ ៦៦-២-២៤៣-៥៥៧៩
Email: seapa@seapabkk.org

ស្តារកម្ពុជា (Star Kampuchea)
ផ្លូវ៥៥ ផ្លូវ១០១ សង្កាត់បឹងត្របែក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៦១២
ទូរសារ (៨៥៥) ២៣ ២១១ ៨១២
អ៊ីម៉ែល ៖ star@starkampuchea.org.kh
វែបសាយ ៖www.starkampuchea.org.kh

**ឧបសម្ព័ន្ធទី២** អនុស្សារណៈស្តីពីច្បាប់កម្ពុជាស្តីពីសារពត៌មានរបស់ អង្គការមាត្រា១៩
(ARTICLE 19 MEMORANDUM ON THE CAMBODIAN LAW ON THE PRESS)